ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២០២ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារ ជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកំណត់និងការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងរបបឧបត្ថម្ភផ្សេងៗជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា១ ._

ប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ត្រូវបានកែប្រែនិងដំឡើងដូចខាងក្រោម៖

ល.រ	បរិយាយ	ប្រាក់បំណាច់មុខងារ(រៀល)
១	អគ្គនាយក	១ ៧៩០ ០០០
២	អគ្គនាយករង	១ ៤៤០ ០០០
៣	ប្រធាននាយកដ្ឋាន	៧៥០ ០០០
៤	អនុប្រធាននាយកដ្ឋាន ប្រធានមណ្ឌលអប់រំកែប្រែ ប្រធានពន្ធនាគាររាជធានី ខេត្ត	៦៥០ ០០០
៥	ប្រធានការិយាល័យថ្នាក់កណ្ដាល អនុប្រធានមណ្ឌលអប់រំកែប្រែ អនុប្រធានពន្ធនាគាររាជធានី ខេត្ត	៥០០ ០០០
៦	អនុប្រធានការិយាល័យថ្នាក់កណ្ដាល ប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ ប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត	៤១០ ០០០
៧	ប្រធានផ្នែកថ្នាក់កណ្ដាល អនុប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ អនុប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត	៣៥០ ០០០
៨	អនុប្រធានផ្នែកថ្នាក់កណ្ដាល ប្រធានផ្នែកមណ្ឌលអប់រំកែប្រែ ប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត	៣១០ ០០០
៩	នាយត្រួតថ្នាក់កណ្ដាល អនុប្រធានផ្នែកមណ្ឌលអប់រំកែប្រែ អនុប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត	២៩០ ០០០
១០	នាយត្រួតរងថ្នាក់កណ្ដាល ប្រធានក្រុមមណ្ឌលអប់រំកែប្រែ ប្រធានក្រុមពន្ធនាគាររាជធានី ខេត្ត	២៨៥ ០០០
១១	អនុប្រធានក្រុមមណ្ឌលអប់រំកែប្រែ អនុប្រធានក្រុមពន្ធនាគាររាជធានី ខេត្ត	២៨០ ០០០
១២	មន្ត្រីពន្ធនាគារ	២៥០ ០០០

មាត្រា២ ._

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តទៅ។

www.pheakdeylaw.com

មាត្រា៣ ..

មាត្រា៤ នៃអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ត្រូវបានជំនួសដោយបទប្បញ្ញត្តិនៃមាត្រា១ នៃអនុក្រឹត្យនេះ។

មាត្រា៤ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី	**ទេសរដ្ឋមន្ត្រី**	
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**	**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
សម្តេចក្រឡាហោម ស ខេង	**អូន ព័ន្ធមុនីរ័ត្ន**	**ពេជ្រ ប៊ុនធិន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com